ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ៦.២៣៣ ដនស/សជក

ភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១១

# ជម្រាបជូន

## លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត

**កម្មវត្ថុ :** ករណីចុះបញ្ជីដីសាធារណៈរបស់រដ្ឋ សម្រាប់គោលដៅនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ចំពោះដីព្រៃអារក្ស ដីកប់ខ្មោច និងដីបម្រុងចម្ការវិលជុំ ។

**យោង :** -អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

-លិខិតលេខ ៧៧/០១១ ដនសស.រត ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តរតនៈគិរី

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី នៃខេត្តដែលមានការពាក់ព័ន្ធនឹងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ជ្រាបថា: បន្ទាប់ពីការអនុវត្តគម្រោងសាកល្បងការចុះបញ្ជីដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តគោលដៅ ០២ នៅខេត្តរតនៈគិរី និង ០១នៅខេត្តមណ្ឌលគិរី ក្រុមការងារបានជួបប្រទះនូវភាពមិនទាន់ច្បាស់លាស់ទាក់ទងនឹងដំណើរការនៃការចុះបញ្ជីដី ដែលស្ថិតនៅក្នុងប្រភេទទ្រព្យសាធារណៈរបស់រដ្ឋ ទៅឱ្យជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ក្នុងន័យនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធ្វើការណែនាំការអនុវត្តការងារនេះតាមនីតិវិធីដូចខាងក្រោម :

១. បើដីសាធារណៈរបស់រដ្ឋ ដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិច ជាដីដែលបានចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋរួចហើយ មន្ទីរត្រូវធ្វើការបំបែកក្បាលដីនោះទៅតាមគោលការណ៍ និងនីតិវិធីជាធរមាននូវចំណែកដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាព ជូនសហគមន៍ជនជាតិដើមភាគតិច។

២. បើដីសាធារណៈរបស់រដ្ឋដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ជាដីមិនទាន់បានចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋនៅឡើយ មន្ទីរត្រូវធ្វើការចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋជូនក្រសួង/ស្ថាប័ន ដែលមានអាណត្តិកាន់កាប់ដីនោះជាមុនសិន រួចទើបធ្វើការបំបែកក្បាលដីនោះ ទៅតាមគោលការណ៍

និងទីតាំងដីជាធរមាននូវចំណែកដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាព ជូនសហគមន៍ជនជាតិដើមភាគតិចជាក្រោយ ។

៣. មន្ទីរត្រូវចុះបញ្ជីនូវចំណែកដីរបស់សហគមន៍ជនជាតិដើមភាគតិច ចូលក្នុងសៀវភៅគោលបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងចេញវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពលើចំណែកដីនោះ ជូនសហគមន៍ជនជាតិដើមភាគតិចតាមការស្នើសុំ។ ទន្ទឹមនេះ នៅលើសៀវភៅគោលបញ្ជីដីថ្មី ឬសៀវភៅចុះបញ្ជីអចលនវត្ថុ និងនៅលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ មន្ទីរត្រូវសរសេរបញ្ជាក់ដោយទឹកក្របាមនៅត្រង់ខ្ទង់សេចក្ដីផ្សេង១ថា **"ទៅវិញ្ញាបនបត្រសម្គាល់សិទ្ធិសមូហភាព លេខ...នៃសហគមន៍ជនជាតិដើមភាគតិច..."** ពោលគឺលេខវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ។ រីឯនៅលើសៀវភៅគោលបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងនៅលើវិញ្ញាបនបត្រសម្គាល់សិទ្ធិសមូហភាព មន្ទីរត្រូវសរសេរបញ្ជាក់ដោយទឹកក្របាមនៅត្រង់ខ្ទង់សេចក្ដីផ្សេង១ថា **"មកពីវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ លេខ..."** ពោលគឺលេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចនវត្ថុដែលជាដីសាធារណៈរបស់រដ្ឋ ។

ខ្លឹមសារដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមន្ទីរមេត្តាជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាព ។

សូមលោកប្រធានមន្ទីរ ទទួលការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

អ៊ឹម ឈុនលឹម

**កន្លែងទទួល:**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន និងអង្គភាពជំនាញចំណុះក្រសួង ដនស

"ជូនជ្រាប និងមុខការ"